# លេខទូរសព្ទទាន់ហេតុការណ៍អំពើហិង្សាក្នុងគ្រួសារ 24 ម៉ោង

| County<br>ខោនធី | Hotline number<br>លេខទូរសព្ទទាន់ហេតុការណ៍ |
|---|---|
| Adams | 717-632-0007 |
| Allegheny | 866-644-2882 |
| Allegheny | 888-299-4673 |
| Allegheny | 866-782-0911 |
| Allegheny | 412-687-8005 |
| Armstrong | 800-841-8881 |
| Beaver | 877-629-1841 |
| Bedford | 800-555-5671 |
| Berks | 844-789-7233 |
| Blair | 800-500-2849 |
| Bradford | 570-265-5333 |
| Bucks | 800-220-8116 |
| Butler | 800-400-8551 |
| Cambria | 800-755-1983 |
| Cameron | 814-486-0952 |
| Carbon | 800-424-5600 |
| Centre | 877-234-5050 |
| Chester | 888-711-6270 |
| Clarion | 800-992-3039 |
| Clearfield | 800-598-3998 |
| Clinton | 570-748-9509 |
| Columbia | 800-544-8293 |
| Crawford | 888-881-0189 |
| Cumberland | 800-852-2102 |
| Dauphin | 800-654-1211 |
| Delaware | 610-565-4590 |
| Elk | 814-772-1227 |
| Erie | 814-438-2675 |
| Erie | 814-454-8161 |
| Fayette | 800-791-4000 |
| Forest | 800-338-3460 |
| Franklin | 800-621-6660 |
| Fulton | 800-621-6660 |
| Greene | 800-791-4000 |
| Huntingdon | 814-643-1190 |
| Indiana | 800-435-7249 |
| Jefferson | 800-598-3998 |
| Juniata | 717-242-2444 |
| Lackawanna | 800-257-5765 |
| Lancaster | 717-299-1249 |
| Lawrence | 724-652-9036 |
| Lebanon | 866-686-0451 |
| Lehigh | 877-438-4957 |
| Luzerne | 800-424-5600 |
| Lycoming | 800-326-8483 |
| McKean | 888-822-6325 |
| Mercer | 888-981-1457 |
| Mifflin | 717-242-2444 |
| Monroe | 570-421-4200 |
| Montgomery | 800-642-3150 |
| Montgomery | 800-773-2424 |
| Montour | 800-544-8293 |
| Northampton | 877-438-4957 |
| Northumberland | 800-850-7948 |
| Perry | 800-852-2102 |
| Philadelphia | 866-723-3014 |
| Pike | 570-253-4401 |
| Potter | 877-334-3136 |
| Schuylkill | 800-282-0634 |
| Snyder | 800-850-7948 |
| Somerset | 800-755-1983 |
| Sullivan | 800-894-3706 |
| Susquehanna | 800-257-5765 |
| Tioga | 800-550-0447 |
| Union | 800-850-7948 |
| Venango | 800-243-4944 |
| Warren | 800-338-3460 |
| Washington | 800-791-4000 |
| Wayne | 570-253-4401 |
| Westmoreland | 888-299-4673 |
| Westmoreland | 888-832-2272 |
| Wyoming | 570-836-5544 |
| York | 800-262-8444 |

**លេខទូរសព្ទទាន់ហេតុការណ៍អំពើហឹង្សាក្នុងគ្រួសារថ្នាក់ជាតិ៖ 1-800-799-SAFE (7233) ឬ TTY 1-800-787-3224**

ការហៅទូរសព្ទទៅលេខទូរសព្ទទាន់ហេតុការណ៍ថ្នាក់ជាតិ នឹងភ្ជាប់អ្នកទៅអ្នកជំនាញណែនាំបន្តសម្រាប់ទូរសព្ទទាន់ហេតុការណ៍កម្មវិធីខោនធីនៅមូលដ្ឋានរបស់អ្នក ។

ទូរសព្ទជំនួយជាការសម្ងាត់ឥតគិតថ្លៃ អាចមាន 24/7 ។ ដើម្បីស្វែងរកកម្មវិធីនៅមូលដ្ឋានរបស់អ្នក និងព័ត៌មានថ្មីៗបំផុត សូមចូលទៅគេហទំព័រ៖
www.pcadv.org/find-help/find-your-local-domestic-violence-program/

# ធនធានសហគមន៍ សម្រាប់សេវាគាំទ្រ

## អ្នកមានសិទ្ធិ ដើម្បីមានសុវត្ថិភាព ។

# តើអំពើហិង្សាក្នុងគ្រួសារជាអ្វី?

អំពើហឹង្សាក្នុងគ្រួសារជាគំរូនៃអាកប្បកិរិយាបំពាននៅក្នុងទំនាក់ទំនងណាមួយដែលប្រើប្រាស់ដោយដៃគូម្នាក់ដើម្បីទទួលបាន ឬរក្សាសិទ្ធិ និងការគ្រប់គ្រងលើដៃគូជិតស្និទ្ធផ្សេងទៀត ។

អំពើហឹង្សាក្នុងគ្រួសារអាចជាសកម្មភាពរាងកាយ ផ្លូវភេទ អារម្មណ៍ សេដ្ឋកិច្ច ផ្លូវចិត្ត ឬបច្ចេកទេស ឬការគំរាមកំហែងលើប្រព័ន្ធផ្សព្វផ្សាយសង្គម និងតាមរយៈការផ្ញើសារនៃសកម្មភាពនានា ឬគំរូផ្សេងទៀតនៃអាកប្បកិរិយាបង្ខិតបង្ខំដែលមានឥទ្ធិពលលើមនុស្សម្នាក់ទៀតនៅក្នុងទំនាក់ទំនងដៃគូជិតស្និទ្ធស្នាល ។ នេះរាប់បញ្ចូលទាំងអាកប្បកិរិយាដែលបំភិតបំភ័យ បញ្ឆោត បំបាក់មុខ ឃ្លាតឆ្ងាយ ភ័យខ្លាច ធ្វើឱ្យតក់ស្លុត បង្ខិតបង្ខំ គំរាមកំហែង ស្តីបន្ទោស ធ្វើឱ្យឈឺចាប់ បង្ករបួសស្នាម ឬរបួសនរណាម្នាក់ ។

ឧទាហរណ៍អាកប្បកិរិយាបំពាន ដែលត្រូវរាប់បញ្ចូល រួមមានជាអាទិ៍ការរំលោភបំពានលើរាងកាយ ការរំលោភបំពានផ្លូវភេទ ការរំលោភបំពានផ្លូវអារម្មណ៍ ការរំលោភបំពានផ្នែកសេដ្ឋកិច្ច ការរំលោភបំពានផ្លូវចិត្ត ការរំលោភបំពានផ្នែកបច្ចេកវិទ្យា ការបៀតបៀនផ្លូវភេទ ការរំលោភផ្លូវភេទ និងការតាមឃ្លាំមើល ។

## ជំនួយការសម្ងាត់អាចមាននៅ CAO មូលដ្ឋានរបស់អ្នក ។

pennsylvania
DEPARTMENT OF HUMAN SERVICES

## សូមទាក់ទងទីភ្នាក់ងារផ្នែកអំពើហិង្សាក្នុងគ្រួសារនៅមូលដ្ឋានរបស់អ្នក ។

មានប្រជាពលរដ្ឋក្នុងសហគមន៍របស់អ្នក ដែលអាចជួយបាន ។ ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកដឹងថាកំពុងរស់នៅជាមួយអំពើ ហិង្សាក្នុងគ្រួសារ សូមទាក់ទងទីភ្នាក់ងារផ្នែកអំពើហឹង្សាក្នុងគ្រួសារនៅមូលដ្ឋានរបស់អ្នក ដែលមានបញ្ជីឈ្មោះនៅក្នុងសៀវភៅនេះ ។ ទីភ្នាក់ងារផ្នែកអំពើហិង្សាក្នុងគ្រួសារផ្តល់ជូនទីជម្រក ការប្រឹក្សាយោបល់ សេវាកម្មផ្នែកច្បាប់ ការធ្វើផែនការសុវត្ថិភាព និងជំនួយផ្សេងៗទៀតដោយឥតគិតថ្លៃ ។ អ្នកអាចទាក់ទងការិយាល័យសេវាកម្មផ្នែកច្បាប់នៅមូលដ្ឋានរបស់អ្នក ដើម្បីស្វែងយល់អំពីសិទ្ធិស្របច្បាប់របស់អ្នក ។ ទាំងអំពើហិង្សាក្នុងគ្រួសារ និងទីភ្នាក់ងារសេវាកម្មផែ្នកច្បាប់ ផ្តល់ជូនសេវាកម្មនានាដែលឥតគិតថ្លៃ និងសម្ងាត់ ។

## សូមទាក់ទងការិយាល័យសេវាកម្មប្រជាពលរដ្ឋ ឬការិយាល័យជំនួយខោនធីនៅមូលដ្ឋានរបស់អ្នក

នៅខណៈពេលអ្នកមិនត្រូវបានទាមទារឱ្យរាយការណ៍អំពីអំពើហិង្សាក្នុងគ្រួសារនោះ អ្នកចង់ពិភាក្សាជាមួយបុគ្គលិកកាន់សំណុំរឿងរបស់អ្នក ដើម្បីទទួលបានជំនួយ ។ បន្ទាប់ពីការភាក្សាជាមួយបុគ្គលិកកាន់សំណុំរឿងរបស់អ្នក អ្នកអាចទទួលបានការលើកលែងពីច្បាប់ស្តីពីកម្មវិធីជាក់លាក់ ប្រសិនបើការគោរពតាមច្បាប់ទាំងនោះ ធ្វើឱ្យអ្នក ឬកូនរបស់អ្នកប្រឈមនឹងគ្រោះថ្នាក់នៃអំពើហិង្សាក្នុងគ្រួសារ ។ សូមចងចាំថាព័ត៌មានណាមួយដែលអ្នកចែករំលែកជាមួយបុគ្គលិកកាន់សំណុំរឿងរបស់អ្នកអំពីអំពើហិង្សាក្នុងគ្រួសារនោះគឺជាការសម្ងាត់ ។

*វិធានកម្មវិធីដូចខាងក្រោមមិនអាចអនុវត្តចំពោះគ្រួសារដែលកំពុងរស់នៅជាមួយអំពើហិង្សាក្នុងគ្រួសារបានទេ ៖*

- *ការងារ*
  អ្នកអាចត្រូវបានលើកលែងជាបណ្តោះអាសន្នពីការធ្វើការងារ ការស្វែងរកការងារធ្វើ ការទៅសាលារៀន ឬការចូលរួមវគ្គបណ្តុះបណ្តាលការងារ ប្រសិនបើសកម្មភាពទាំងនេះដាក់ឱ្យអ្នក ឬកូនរបស់អ្នកស្ថិតក្នុងគ្រោះថ្នាក់នៃអំពើហិង្សាក្នុងគ្រួសារ ។
- *ការគាំទ្រកុមារ*
  អ្នកអាចទទួលបានការលើកលែងពីច្បាប់ស្តីពីការគាំទ្រកូនជាក់លាក់ ប្រសិនបើមានការផ្តល់ព័ត៌មានអំពីឪពុករបស់កូនអ្នក ឬការទៅតុលាការសម្រាប់ការគាំទ្រកុមារ ធ្វើឱ្យអ្នកនិងក្រុមគ្រួសាររបស់អ្នកស្ថិតក្នុងគ្រោះថ្នាក់ ។
- *ឪពុកម្តាយវ័យជំទង់*
  ប្រសិនបើអ្នកជាឪពុកម្តាយដែលមិនទាន់បានរៀបការមានអាយុក្រោមអាយុ 18 ឆ្នាំ អ្នកអាចនឹងមិនត្រូវបានតម្រូវឲ្យរស់នៅជាមួយឪពុកម្តាយរបស់អ្នក ឬមនុស្សពេញវ័យម្នាក់ទៀតទេ ប្រសិនបើការរស់នៅជាមួយបុគ្គលនោះបង្កគ្រោះថ្នាក់ចំពោះអ្នក ឬកូនរបស់អ្នក ។
- *ការកំណត់ពេលវេលា*
  អ្នកអាចត្រូវបានគេលើកលែងពីការកំណត់ពេលវេលាជំនួយសាច់ប្រាក់ជាក់លាក់ ។

យើងខ្ញុំយល់ថាការពិភាក្សាអំពីអំពើហិង្សាក្នុងគ្រួសារជារឿងផ្ទាល់ខ្លួន ។ អ្នកអាចស្នើសុំនិយាយប្រាប់បុគ្គលិកកាន់សំណុំរឿងរបស់អ្នកជាលក្ខណៈឯកជនអំពីអំពើហិង្សាក្នុងគ្រួសារគ្រប់ពេលវេលា ទោះបីជាអ្នកប្រហែលជាពិបាកនិយាយអំពីវាឥឡូវនេះក៏ដោយ ។ វាមានសារៈសំខាន់ណាស់ ដើម្បីទទួលបានជំនួយ ។ ទោះបីជាអ្នកនិយាយប្រាប់បុគ្គលិកកាន់សំណុំរឿងរបស់អ្នកអំពីអំពើហិង្សាក្នុងគ្រួសារនៅថ្ងៃក្រោយក៏ដោយ ក៏អ្នកនៅតែអាចទទួលបានការលើកលែងពីច្បាប់ស្តីពីកម្មវិធីជាក់លាក់នៅពេលនោះផងដែរ ។

**សូមហៅទូរសព្ទលេខ 911 ប្រសិនបើអ្នកមានគ្រោះថ្នាក់ភ្លាមៗ!**